**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ សសរ

# សេចក្តីសំរេច

## ស្តីអំពីរបៀបរបបការងារ និង ការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ។

**ប្រការ ២** : ចំពោះនាយករដ្ឋមន្ត្រី : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** : នាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំរួមការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែងបញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ និងទទួលផ្ទាល់លើការងារគ្រប់គ្រងគ្រោះមហន្តរាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៣** : ចំពោះឧបនាយករដ្ឋមន្ត្រី :

១-ឯកឧត្តម **ស ខេង** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលអវត្តមាននាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភេរវកម្ម ដឹកនាំគណៈកម្មាធិការជាតិកែទំរង់វិមជ្ឈការ និងសហវិមជ្ឈការ (គជវវ) ការបំផ្លាញចោលអាវុធ ។

២-ឯកឧត្តម **សុខ អាន** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការសំរាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដានសម្របសម្រួល និងដឹកនាំកិច្ចការកែទំរង់រដ្ឋ ដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ព័ត៌មានវិទ្យា ដឹកនាំផ្ទាល់អាជ្ញាធរប្រេងកាតជាតិកម្ពុជា អាជ្ញាធរអប្សារា គណៈកម្មការយូនេស្កូ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ក្រុមប្រឹក្សាកំសាយកងកំលាំងប្រដាប់អាវុធ គណៈតម្មាធិការទទួលស្គាល់គុណភាពអប់រំ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ជួយនាយករដ្ឋមន្ត្រី ក្នុងការរៀបចំចម្លើយតបនឹងសំនួររបស់សមាជិករដ្ឋសភាតាមនីតិវិធី ដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដានសម្របសម្រួលការងាររបស់ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ។

៣-ឯកឧត្តម **ទៀ បាញ់** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការពារជាតិ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការងារបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដឹកនាំកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាអង្គភាពពិសេសប្រឆាំងភេរវកម្មក្នុងពេលអវត្តមាននាយករដ្ឋមន្ត្រី ។

៤-ឯកឧត្តម **ហោ ណាំហុង** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការបរទេស និងសហប្រតិបត្តិការអន្តរជាតិទូទៅ ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដានសម្របសម្រួលការងាររបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

៥-លោកជំទាវ **ម៉ែន សំអន** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារសង្គម និងក្នុងការតាមដានសម្របសម្រួលការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី ។

៦-ឯកឧត្តម **ប៊ិន ឈិន** :ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ការងារអធិការកិច្ច ការការពារទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដានសម្របសម្រួលការងាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ ។

៧-ឯកឧត្តម **ញឹក ប៊ុនឆៃ** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំគណៈកម្មការត្រួតពិនិត្យដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង (ចំណុះឱ្យគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន) ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដានសម្របសម្រួលការងាររបស់ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងធម្មការ និងសាសនា ។

៨-ឯកឧត្តម គាត ឈន់ : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដានសម្របសម្រួលការងាររបស់ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

៩-ឯកឧត្តម យឹម ឆៃលី : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដាន សម្របសម្រួលការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

១០-ឯកឧត្តម កែ គឹមយ៉ាន : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ប្រការ ៤ : នាយករដ្ឋមន្ត្រី និង ឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារតាមការកោះអញ្ជើញពីនាយករដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីស្តីទី ។

ប្រការ ៥ : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកអនុវត្តការងារ ឬបេសកកម្មផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូនស្របតាមមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : ឧបនាយករដ្ឋមន្ត្រី ១ រូបៗ មានទីប្រឹក្សា ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ. ២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងជំនួយការ ៣ រូប ក្នុងនោះ ១ រូប មានឋានៈស្មើ អគ្គនាយក. ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

ប្រការ ៧ : ចំពោះទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ÷

១-ឯកឧត្តម ញឹម វណ្ណដា : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

២-ឯកឧត្តម តាវ សេងហួរ : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដឹកនាំការងាររបស់អាជ្ញាធរអាងទន្លេសាប និងការងាររបស់គណៈកម្មាធិការជាតិ ដើម្បីប្រជាជន ។

៣-ឯកឧត្តម ឃួន ឃាំង : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការសាសនា និងធម្មការ និងជាអនុប្រធានប្រចាំការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៤-ឯកឧត្តម លី ធួច : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងទទួលបន្ទុក ESCAP ។

៥-ឯកឧត្តម ភួល ផេង : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីអំពីការងារអប់រំ ។

៦-ឯកឧត្តម ម៉ែង សិរីវុឌ្ឍ : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ។

៧-ឯកឧត្តម ស៊ុន ចាន់ថុល : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីអំពីការងារសាធារណការ និងដឹកជញ្ជូន វិនិយោគ និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៨-ឯកឧត្តម នួត សុខុម : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ។

៩-ឯកឧត្តម ឱម យិនទៀង : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំគណៈកម្មការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល និងអង្គភាពប្រឆាំងអំពើពុករលួយ ។

១០-ឯកឧត្តម អៀង មូលី : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីអំពីការងារមីន ។

១១-ឯកឧត្តម វ៉ា គឹមហុង : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន ។

១២-ឯកឧត្តម យឹម ឆៃលី : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកការងារក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

១៣-ឯកឧត្តម សេរី កុសល : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកអនុប្រធានប្រចាំការគណៈកម្មាធិការជាតិជំរុញចលនាភូមិ ១ ផលិតផល ១ ។

**ប្រការ ៨ :** ទេសរដ្ឋមន្ត្រីទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៩ :** ទេសរដ្ឋមន្ត្រី ១ រូបៗ មានជំនួយការ ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើ អគ្គនាយក និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ១០:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១:** នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*__កន្លែងទទួល__*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ដូចប្រការ ៣, ៧ និង ១១*
*-ឯកសារ-កាលប្បវត្តិ*